ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

សាលាដំបូងខេត្តមណ្ឌលគិរី

សំណុំរឿងរដ្ឋប្បវេណីលេខ ៖ ១៧
ចុះថ្ងៃទី ១៧ ខែ មីនា ឆ្នាំ ២០២១
សញ្ញាណនៃរឿងក្តី៖ ទាមទារចុះ
បញ្ជីផ្ទេរកម្មសិទ្ធិអចលនវត្ថុ
សាលក្រមរដ្ឋប្បវេណីលេខ ៖ ២២
ចុះថ្ងៃទី ១១ ខែ វិច្ឆិកា ឆ្នាំ ២០២១

# សាលក្រម

## ក្នុងនាមប្រជារាស្ត្រខ្មែរ

## សាលាដំបូងខេត្តមណ្ឌលគិរី

បានបញ្ចប់នីតិវិធីទាញហេតុផលដោយផ្ទាល់មាត់នៅថ្ងៃទី២៦ ខែតុលា ឆ្នាំ២០២១
បានប្រកាសសាលក្រម នៅថ្ងៃទី១១ ខែវិច្ឆិកា ឆ្នាំ២០២១

**ចៅក្រមជំនុំជម្រះ**

លោកស្រី [redacted] ចៅក្រមសាលាដំបូងខេត្តមណ្ឌលគិរី

**ក្រឡាបញ្ជី**

លោកស្រី [redacted] ក្រឡាបញ្ជីនៃសាលាដំបូងខេត្តមណ្ឌលគិរី

**ដើមចោទ ÷**

-ឈ្មោះ [redacted] ម្រុស ភេទប្រុស កើតនៅថ្ងៃទី ០៧ ខែមេសា ឆ្នាំ១៩៨២ សញ្ជាតិខ្មែរ មានទីលំនៅបច្ចុប្បន្ន នៅភូមិ [redacted] ។

-មានមេធាវីតំណាងដោយអាណត្តិលោកស្រី [redacted] មានអត្តលេខ ២២៤៩ T ដោយមានគ្រូកម្មសិក្សាលោកមេធាវី [redacted] ជាមេធាវីនៃគណៈមេធាវីនៃព្រះរាជាណាចក្រកម្ពុជា ដែលមានការិយាល័យស្ថិតនៅផ្ទះលេខ [redacted]។

**សហចុងចម្លើយ ÷**

-ឈ្មោះ [redacted] សំណាង ភេទប្រុស កើតនៅថ្ងៃទី ១៥ ខែតុលា ឆ្នាំ១៩៧៥ សញ្ជាតិខ្មែរ មានទីលំនៅបច្ចុប្បន្ននៅភូមិ [redacted] ។

-ឈ្មោះ [redacted] ស៊ីដា ភេទស្រី កើតនៅថ្ងៃទី១១ ខែវិច្ឆិកា ឆ្នាំ១៩៨០ សញ្ជាតិខ្មែរ មានទីលំនៅបច្ចុប្បន្ន នៅភូមិ [redacted] ។

-មេធាវីតំណាងដោយអាណត្តិ "គ្មាន" ។

**អង្គហេតុ និង ចំណុចវិវាទ**

**១. ខ្លឹមសារនៃសាលក្រមដែលដើមចោទទាមទារ ÷**

១.បង្គាប់ឲ្យចុងចម្លើយធ្វើនីតិវិធីផ្ទេរចុះបញ្ជីផ្ទេរកម្មសិទ្ធិលើអចលនវត្ថុលើដី ដែលមានទីតាំងស្ថិតនៅភូមិពូរាំង ឃុំប៊ូស្រា ស្រុកពេជ្រាដា ខេត្តមណ្ឌលគិរី ដែលមានវិញ្ញាបនបត្រសម្គាល់ម្ចាស់៤'

អចលនវត្ថុលេខ១១០៤០៤០២-០០០១ មកឱ្យដើមចោទ។

២.បង្គាប់ឱ្យចុងចម្លើយទទួលបន្ទុករាល់ការចំណាយលើនីតិវិធីផ្ទេរចុះបញ្ជីអចលនវត្ថុ(ប្លង់រឹង)

៣.សងសំណងការខូចខាតមិនអនុវត្តកាតព្វកិច្ច ២០.០០០.០០០ រៀល។

៤.ប្រាក់ប្រដាប់ក្តីជាបន្ទុករបស់ចុងចម្លើយ។

**២. អំពីដំណើររឿងក្តី និងចំណុចវិវាទ**

**២.១. ការសង្ខេបអំពីរឿងក្តី**

នៅថ្ងៃទី ០៧ ខែមេសា ឆ្នាំ២០១៦ ដើមចោទបានទិញដីមួយកន្លែងមានទំហំ ១៦,៩១៥ ម៉ែត្រការ៉េ ស្ថិតនៅភូមិពូរាំង ឃុំប៊ូស្រា ស្រុកពេជ្រាដា ខេត្តមណ្ឌលគិរី ក្នុងតម្លៃ ៥០០ ដុល្លារអាមេរិក ក្នុងមួយម៉ែត្រក្បាលដីដែលមានវិញ្ញាបនបត្រសម្គាល់ម្ចាស់អចលនវត្ថុលេខ ១១០៤០៤០២-០០០១ ចុះថ្ងៃទី១៤ ខែវិច្ឆិកា ឆ្នាំ២០១២ ពីចុងចម្លើយដោយមានធ្វើជាកិច្ចសន្យាលក់ផ្តាច់ចុះថ្ងៃទី ០៧ ខែមេសា ឆ្នាំ២០១៦។ ដោយក្នុងកិច្ចសន្យាលក់ផ្តាច់បានកំណត់ថា ចុងចម្លើយត្រូវប្រគល់ និងចុះបញ្ជីអចលនវត្ថុនៅនៅមន្ទីររៀបចំដែនដីនគរូបនីយកម្ម សំណង់ និងសុរិយោដីខេត្តមណ្ឌលគិរី ប៉ុន្តែអស់រយៈពេលជាង ០៤ឆ្នាំ ១០ខែ កន្លងផុតទៅ ចុងចម្លើយមិនបានអនុវត្តកាតព្វកិច្ច ថែមទាំងគេចវេសមិនដោះស្រាយទៀតផង។

**២.២. ការអះអាងរបស់គូភាគីចំពោះចំណុចវិវាទ**

**១. ចំពោះចំណុចវិវាទទី១៖**

ក.ការអះអាងរបស់ដើមចោទ

ដើមចោទបានទាមទារឱ្យតុលាការចេញសាលក្រមបង្គាប់ឱ្យចុងចម្លើយធ្វើនីតិវិធីផ្ទេរកម្មសិទ្ធិអចលនវត្ថុដោយផ្អែកលើកិច្ចសន្យាលក់ផ្តាច់លេខ ០៩០/១៦ បស ចុះថ្ងៃទី០៧ ខែមេសា ឆ្នាំ២០១៦ របស់លោកមេឃុំប៊ូស្រា។

ខ. ការអះអាងរបស់សហចុងចម្លើយ៖ សហចុងចម្លើយ (អវត្តមាន) ។

គ. អង្គហេតុវិវាទ៖គ្មាន ។

**២. ចំណុចវិវាទទី២៖**

ក. ការអះអាងរបស់ដើមចោទ

ដើមចោទបានទាមទារឱ្យចុងចម្លើយទទួលបន្ទុករាល់ការចំណាយលើនីតិវិធីផ្ទេរកម្មសិទ្ធិអចលនវត្ថុ ដោយផ្អែកក្នុងកិច្ចសន្យាលក់ផ្តាច់ចុះថ្ងៃទី ០៧ ខែមេសា ឆ្នាំ២០១៦ បានកំណត់ថា ចុងចម្លើយត្រូវប្រគល់ និងចុះបញ្ជីអចលនវត្ថុនៅមន្ទីររៀបចំដែនដីនគរូបនីយកម្ម សំណង់ និងសុរិយោដីខេត្តមណ្ឌលគិរី ប៉ុន្តែអស់រយៈពេលជាង ០៤ឆ្នាំ ១០ខែ កន្លងផុតទៅ ចុងចម្លើយមិនបានអនុវត្តកាតព្វកិច្ច ថែមទាំងគេចវេសមិនដោះស្រាយ ដែលជាហេតុនាំឱ្យដើមចោទខាតបង់ពេលវេលា ថវិកា និងមិនអាចប្រើប្រាស់វិញ្ញាបនបត្រដែលបានទិញនេះក្នុងកិច្ចការប្រកបជំនួញនានា។

ខ. ការអះអាងរបស់សហចុងចម្លើយ ៖ សហចុងចម្លើយអវត្តមាន។

គ. អង្គហេតុវិវាទ៖ គ្មាន។



Scanned with CamScanner

៣. ចំណុចវិវាទទី៣៖

ក. ការអះអាងរបស់ដើមចោទ

ដើមចោទបានខ្ចីប្រាក់ពីធនាគារ ត្រូវការបង់ការប្រាក់ចំនួន ០,៧% ក្នុងមួយខែ ស្មើនឹង ៣០០ ដុល្លារអាមេរិក ហើយខកខានក្នុងបង់ការប្រាក់រយៈពេល ២ឆ្នាំ ដោយសារតែចុងចម្លើយមិនព្រមអនុវត្តតាមកិច្ចសន្យាលក់ផ្តាច់។

ខ. ការអះអាងរបស់សហចុងចម្លើយ ៖ សហចុងចម្លើយអវត្តមាន។

គ. អង្គហេតុវិវាទ៖ គ្មាន។

*បានឃើញ៖*

- ដីកាកោះចុងចម្លើយ ឈ្មោះ [redacted] ស៊ីផា ឲ្យចូលមកក្នុងនីតិវិធីទាញហេតុផលដោយផ្ទាល់មាត់ចុះថ្ងៃទី ១២ ខែតុលា ឆ្នាំ២០២១។
- ដីកាកោះចុងចម្លើយ ឈ្មោះ [redacted] សំណាង ឲ្យចូលមកក្នុងនីតិវិធីទាញហេតុផលដោយផ្ទាល់មាត់ចុះថ្ងៃទី១២ ខែតុលា ឆ្នាំ២០២១។
- ដីកាកោះចុងចម្លើយ ឈ្មោះ [redacted] ស៊ីផា ឲ្យចូលមកក្នុងនីតិវិធីត្រៀមសម្រាប់ការទាញហេតុផលដោយផ្ទាល់មាត់ចុះថ្ងៃទី៣០ ខែមិថុនា ឆ្នាំ២០២១។
- ដីកាកោះចុងចម្លើយ ឈ្មោះ [redacted] សំណាង ឲ្យចូលមកក្នុងនីតិវិធីទាញហេតុផលដោយផ្ទាល់មាត់ចុះថ្ងៃទី៣០ ខែមិថុនា ឆ្នាំ២០២១។

## សំអាងហេតុ

តាមលទ្ធផលនៃការទាញហេតុផលដោយផ្ទាល់មាត់ និង ការពិនិត្យភស្តុតាងជាសម្ភារៈ យល់ឃើញថា៖

១. តាមរយៈដីកាកោះហៅសហចុងចម្លើយឈ្មោះ [redacted] សំណាង និង ឈ្មោះ [redacted] ស៊ីផា ឲ្យចូលមកក្នុងនីតិវិធីត្រៀមសម្រាប់ការទាញហេតុផល និង នីតិវិធីនៃការទាញហេតុផលកន្លងមកដូច តាមដីកាកោះហៅដូចមាននៅក្នុងសំណុំរឿងឃើញថា សហចុងចម្លើយទាំងពីរនាក់បានទទួលការបញ្ជូន និង បានទទួលដំណឹងអំពីកាលបរិច្ឆេទនៃនីតិវិធី ប៉ុន្តែបានព្យាយាមគេចវេសមិនចូលរួមនីតិវិធីបើទោះបីជាតុលាការបានសម្រេចលើកពេល និងកំណត់កាលបរិច្ឆេទថ្មីម្តងហើយម្តងទៀត ដោយពុំមានមូលហេតុសមរម្យ។ ហេតុនេះតុលាការបានសម្រេចបន្តនីតិវិធី ស្របតាមបញ្ញត្តិមាត្រា ២០១ នៃក្រមនីតិវិធីរដ្ឋប្បវេណី។

២. ចំពោះការទាមទារចំណុចទី១៖

ក.មេធាវីតំណាងដោយអាណត្តិឲ្យដើមចោទបានធ្វើសេចក្តីថ្លែងការណ៍ទាមទារឲ្យចេញសាលក្រមបង្គាប់សហចុងចម្លើយធ្វើនីតិវិធីចុះបញ្ជីផ្ទេរកម្មសិទ្ធិអចលនវត្ថុ ដែលមានទីតាំងស្ថិតនៅភូមិពូរាំង ឃុំប៊ូស្រា ស្រុកពេជ្រាដា ខេត្តមណ្ឌលគិរី ដោយផ្អែកលើកិច្ចសន្យាលក់ផ្តាច់លេខ ០៩០/១៦ បស ចុះថ្ងៃទី ០៧ ខែមេសា ឆ្នាំ ២០១៦ របស់លោកមេឃុំប៊ូស្រា។



Scanned with CamScanner

ខ. តាមការពិនិត្យលើកិច្ចសន្យាលក់ផ្ដាច់លេខ ០៩០/១៦ បស ចុះថ្ងៃទី ០៧ ខែមេសា ឆ្នាំ២០១៦ ឃើញថាជាលិខិតយថាភូតដែលបញ្ជាក់បានថា កាលពីថ្ងៃទី០៧ ខែមេសា ឆ្នាំ២០១៦ ដើមចោទឈ្មោះ [redacted] ប្រុស បានទិញដីមួយកន្លែងមានទំហំទទឹងប្រវែង៥៨ ម៉ែត្រ ដែលមានវិញ្ញាបនបត្រសម្គាល់ម្ចាស់អចលនវត្ថុលេខ ១១០៥០៥០២-០០០១ ចុះថ្ងៃទី១៤ ខែវិច្ឆិកា ឆ្នាំ២០១២ ស្ថិតនៅភូមិពូរាំង ឃុំប៊ូស្រា ស្រុកពេជ្រាដា ខេត្តមណ្ឌលគិរី ពីសហចុងចម្លើយឈ្មោះ [redacted] សំណាង និងប្រពន្ធឈ្មោះ [redacted] ស៊ីផា ប្រាកដមែន។ និងតាមរយៈបង្កាន់ដៃដកប្រាក់របស់ឈ្មោះ [redacted] ប្រុស ចុះថ្ងៃទី ០៨ ខែមេសា ឆ្នាំ២០១៦ របស់ធនាគារអេស៊ីលីដា អាចបញ្ជាក់បានថាដើមចោទ [redacted] ន ប្រុស ពិតជាបានបង់ប្រាក់ថ្លៃទិញដីឱ្យទៅចុងចម្លើយរួចរាល់។

គ. តាមការពិនិត្យលើលិខិតបំភ្លឺចុះថ្ងៃទី២៨ ខែកក្កដា ឆ្នាំ២០២១ របស់ចុងចម្លើយឈ្មោះ [redacted] សំណាង ឃើញថាចុងចម្លើយបានទទួលស្គាល់ថាខ្លួនពិតជាបានលក់ដីឱ្យទៅដើមចោទក្នុងទំហំទទឹងប្រវែង ៥៨ ម៉ែត្រ និង បណ្ដោយដល់ក្បាលដីរបស់ឈ្មោះ [redacted] សាមឿន និង ពន់សំណាងពិតប្រាកដមែន។

ដូច្នេះយល់ឃើញថា ដើមចោទឈ្មោះ [redacted] ប្រុស ពិតជាមានអត្ថិភាពនៃសិទ្ធិកម្មសិទ្ធិលើដីទំហំទទឹងប្រវែង ៥៨ម៉ែត្រ និង បណ្ដោយជាប់ក្បាលដីរបស់ឈ្មោះ [redacted] មឿន និងឈ្មោះ [redacted] សំណាង ស្ថិតនៅភូមិពូរាំង ឃុំប៊ូស្រា ស្រុកពេជ្រាដា ខេត្តមណ្ឌលគិរី តាមរយៈកិច្ចសន្យាលក់ទិញអចលនវត្ថុ។

**២. ចំពោះការទាមទារចំណុចទី២**

ក.មេធាវីតំណាងដោយអាណត្តិឱ្យដើមចោទបានធ្វើសេចក្ដីថ្លែងការណ៍ដោយទាមទារឱ្យចុងចម្លើយត្រូវទទួលបន្ទុកថ្លៃ ចុះបញ្ជីផ្ទេរកម្មសិទ្ធិលើអចលនវត្ថុវិវាទពីឈ្មោះសហចុងចម្លើយ មកឱ្យដើមចោទ ដែលត្រូវជាប្រាក់ចំនួន ៤.០០០ ដុល្លារអាមេរិក។

ខ.ផ្អែកតាមបញ្ញត្តិមាត្រា ៤៤៦ នៃក្រមរដ្ឋប្បវេណី ក្នុងករណីដែលគ្មានការព្រមព្រៀងអំពីសោហ៊ុយនៃការសងទេនោះ កូនបំណុលជាអ្នកទទួលបន្ទុកសោហ៊ុយនេះ។ អាស្រ័យតាមបញ្ញត្តិមាត្រានេះ ឃើញថាសហចុងចម្លើយជាអ្នកលក់ត្រូវទទួលបន្ទុកលើការចំណាយចំពោះការចុះបញ្ជីផ្ទេរកម្មសិទ្ធិលើអចលនវត្ថុដែលបានលក់ មកឱ្យដើមចោទដែលជាអ្នកទិញ។

**៣. ចំពោះការទាមទារចំណុចទី៣**

ក.មេធាវីតំណាងដោយអាណត្តិឱ្យដើមចោទបានទាមទារ សំណងការខូចខាតចំពោះការប្រាក់លើប្រាក់កម្ចីដោយសារចុងចម្លើយមិនបានធ្វើការចុះបញ្ជីផ្ទេរកម្មសិទ្ធិលើអចលនវត្ថុវិវាទមកឱ្យដើមចោទចំនួន ២០.០០០.០០០ (ម្ភៃលាន)រៀល។ ក៏ប៉ុន្តែចំពោះការទាមទារចំណុចនេះខាងដើមចោទ មិនបានបង្ហាញភស្តុតាង ឬឯកសារនានាដើម្បីមកបញ្ជាក់អំពីការទាមទារនោះឡើយ។

ខ. ផ្អែកតាមបញ្ញត្តិមាត្រា១២៣ រហូតដល់មាត្រា ១២៦ នៃក្រមនីតិវិធីរដ្ឋប្បវេណី តៅក្រមត្រូវសម្រេចសេចក្ដីដោយផ្អែកលើភស្តុតាង។ ហេតុដូចនេះការទាមទាររបស់ដើមចោទត្រង់ចំណុចនេះ មិនគប្បីលើកមកពិចារណានោះឡើយ។



Scanned with CamScanner

៤. ផ្អែកតាមបញ្ញត្តិមាត្រា ៦៤ និងមាត្រា ៦៥ នៃក្រមនីតិវិធីរដ្ឋប្បវេណី តុលាការត្រូវសម្រេចអំពីប្រាក់ប្រដាប់ក្តី ។

## សេចក្តីសម្រេចបញ្ចប់

១- បង្គាប់ឱ្យសហចុងចម្លើយឈ្មោះ [redacted] សំណាង និងឈ្មោះ [redacted] ស៊ីផា ធ្វើនីតិវិធីចុះបញ្ជីផ្ទេរកម្មសិទ្ធិលើអចលនវត្ថុ ស្ថិតនៅភូមិពូរាំង ឃុំប៊ូស្រា ស្រុកពេជ្រាដា ខេត្តមណ្ឌលគិរី ដែលមានទទឹង ៥៨ ម៉ែត្រ និងបណ្តោយជាប់ក្បាលដីរបស់ឈ្មោះ [redacted] មឿន និងឈ្មោះ [redacted] សំណាង នៃវិញ្ញាបនបត្របណ្ណ័សម្គាល់ម្ចាស់អចលនវត្ថុលេខ ១១០៤០៤០២-០០០១ ចុះថ្ងៃទី១៤ ខែ វិច្ឆិកា ឆ្នាំ២០១២ ឱ្យទៅដើមចោទឈ្មោះ [redacted] ប្រុស ។

២-បង្គាប់ឱ្យសហចុងចម្លើយទទួលបន្ទុកលើការចំណាយលើនីតិវិធីចុះបញ្ជីផ្ទេរកម្មសិទ្ធិ ដោយត្រូវបង់ប្រាក់ឱ្យទៅដើមចោទចំនួន ៤.០០០ (បួនពាន់) ដុល្លាររអាមេរិក ។

៣-ច្រានចោលការទាមទារចំណុចទី៣ ។

៤-ប្រាក់ប្រដាប់ក្តីជាបន្ទុករបស់សហចុងចម្លើយ។

សាលក្រមនេះ បានទាញហេតុផលដោយផ្ទាល់មាត់នៅថ្ងៃទី២៦ ខែតុលា ឆ្នាំ២០២១ និងប្រកាសជាសាធារណៈនៅថ្ងៃទី១១ ខែវិច្ឆិកា ឆ្នាំ២០២១ ចំពោះមុខដើមចោទ និងកំបាំងមុខសហចុងចម្លើយ។

ទុកសិទ្ធិប្តឹងទាស់ និងប្តឹងឧទ្ធរណ៍តាមកំណត់ច្បាប់។

**ចៅក្រមជំនុំជម្រះ**

**ហត្ថលេខា និងត្រា:** [redacted]

---

**បានឃើញ**

**ចៅក្រមជំនុំជម្រះ**

[redacted]

បានចម្លងត្រឹមត្រូវតាមច្បាប់ដើម

ថ្ងៃព្រហស្បត្តិ៍ ៧កើត ខែកត្តិក ឆ្នាំឆ្លូវ ត្រីស័ក ព.ស ២៥៦៥

ធ្វើនៅមណ្ឌលគិរី ថ្ងៃទី ១១ ខែវិច្ឆិកា ឆ្នាំ២០២១

**ក្រឡាបញ្ជី**

[redacted]



Scanned with CamScanner